ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ១៥ អយក.សប្រ៣

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
## ផលប៉ះពាល់នៃការឈ្លានពានយោធាខុសច្បាប់របស់ប្រទេសថៃ លើការរៀនសូត្ររបស់កុមារកម្ពុជា

ដោយសារការឈ្លានពានយោធាខុសច្បាប់ និងគួរស្អប់ខ្ពើមរបស់ប្រទេសថៃ មកលើអធិបតេយ្យ និងបូរណភាពនៃព្រះរាជាណាចក្រកម្ពុជា គិតមកដល់ត្រឹមថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០២៥ សាលារៀនចំនួន **៥១៤កន្លែង** បានបិទទ្វារ ធ្វើឱ្យប៉ះពាល់ដល់ការសិក្សារបស់សិស្សប្រមាណ **១៣ម៉ឺននាក់** និងការបំពេញការងាររបស់គ្រូបង្រៀន **៤,៦៥០នាក់**។

**១. ខេត្តព្រះវិហារ**

ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ទទួលរងផលប៉ះពាល់ទាំងស្រុង ដែលធ្វើឱ្យសាលារៀនចំនួន **៦១** ផ្អាកដំណើរការ និងប៉ះពាល់ដល់ការសិក្សារបស់សិស្សចំនួន **១៣,៦៦៥នាក់** គ្រូបង្រៀនចំនួន **៤៩៣នាក់**។

**២. ខេត្តឧត្តរមានជ័យ**

ខេត្តឧត្តរមានជ័យ ទទួលរងផលប៉ះពាល់ទាំងស្រុង ដែលធ្វើឱ្យសាលារៀនចំនួន **២៦០** ផ្អាកដំណើរការ និងប៉ះពាល់ដល់ការសិក្សារបស់សិស្សចំនួន **៥៥,៧៣១នាក់** គ្រូបង្រៀនចំនួន **២,៣៤៤នាក់**។ សាលារៀននៅជាប់ព្រំដែនចម្ងាយ ១០ គីឡូម៉ែត្រ មានចំនួន **៣២សាលា** ក្នុងនោះមានស្រុកបន្ទាយអំពិលចំនួន ៨ ក្រុងសំរោងចំនួន **១២** ស្រុកអន្លង់វែងចំនួន ៤ និងស្រុកត្រពាំងប្រាសាទចំនួន ៨។

**៣. ខេត្តបន្ទាយមានជ័យ**

សាលារៀនសរុប **១៨៦** ក្នុងក្រុង ស្រុកចំនួន **៥** ក្នុងខេត្តបន្ទាយមានជ័យ បានផ្អាកដំណើរការ និងប៉ះពាល់ដល់ការសិក្សារបស់សិស្សចំនួន **៥៨,៧៥៤នាក់** គ្រូបង្រៀនចំនួន **១,៧៩០នាក់**។

**៤. ខេត្តពោធិ៍សាត់**

សាលារៀនចំនួន **៥** ក្នុងស្រុកវាលវែង ខេត្តពោធិ៍សាត់ បានផ្អាកដំណើរការ និងប៉ះពាល់ដល់ការសិក្សារបស់សិស្សចំនួន **៨៩១នាក់** គ្រូបង្រៀនចំនួន **២០នាក់**។ ក្នុងនោះ វិទ្យាល័យប្រម៉ោយ និងវត្តប្រម៉ោយ ត្រូវបានយកជាទីតាំងស្នាក់នៅបណ្តោះអាសន្ន របស់ប្រជាពលរដ្ឋដែលភៀសសឹកមកពីឃុំថ្មដា។

**៥. ខេត្តកោះកុង**

សាលារៀនចំនួន **២** ក្នុងស្រុកមណ្ឌលសីមា ខេត្តកោះកុង បានផ្អាកដំណើរការ និងប៉ះពាល់ដល់ការសិក្សារបស់សិស្សចំនួន **៥៥នាក់** គ្រូបង្រៀនចំនួន **៣នាក់**។

**៦. ខេត្តបាត់ដំបង**

សាលារៀនក្នុងស្រុកចំនួន ៤ នៅខេត្តបាត់ដំបង ជាប់ព្រំដែនកម្ពុជា-ថៃ រួមមានស្រុកសំឡូត ស្រុកសំពៅលូន ស្រុកកំរៀង និងស្រុកភ្នំព្រឹក ពុំទាន់ផ្អាកដំណើរការនៅឡើយទេ ប៉ុន្តែសិស្សអវត្តមានច្រើន។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមសាធារណជនមេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃ អង្គារ ៤រោច ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ៩ ខែ ធ្នូ ឆ្នាំ២០២៥

អាសយដ្ឋានៈ អគារលេខ ៨០ មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ កម្ពុជា
info@moeys.gov.kh / administration@moeys.gov.kh
ទូរស័ព្ទៈ (+៨៥៥) ២៣ ២២០ ៦៧៣ / ២២០ ៣០៤
www.moeys.gov.kh